ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលព្រៃឈើ



# ស្ថិតិសហគមន៍ព្រៃឈើកម្ពុជា ឆ្នាំ២០១៣

ខែមិថុនា ឆ្នាំ២០១៣

# អារម្ភកថា

ធនធានព្រៃឈើដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនិងបរិស្ថាន ជាពិសេស បានផ្តល់សារប្រយោជន៍យ៉ាងច្រើនក្រៃលែងដល់សង្គមជាតិយើងតាំងពីដើមរហូតមកដល់បច្ចុប្បន្ននិង ទៅអនាគត។ព្រៃឈើជួយថែរក្សាការពារលំនឹងបរិស្ថានធម្មជាតិធ្វើឲ្យធាតុអាកាស មានភាពកាន់តែ ប្រសើរឡើងធ្វើឲ្យខ្យល់បរិសុទ្ធរក្សាបាននូវនិយ័តភាពប្រភពទឹកការពារទីជម្រាលនិងជីវចម្រុះព្រមទាំង ចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នទៅបរិយាកាស និងជួយទ្រទ្រង់ជីវភាពរស់នៅសម្រាប់ប្រជាពល រដ្ឋរាប់លាននាក់ដែលពឹងអាស្រ័យទៅលើផលអនុផលព្រៃឈើ។ហេតុនេះប្រជាពលរដ្ឋគ្រប់រូបត្រូវមាន កាតព្វកិច្ចថែរក្សាការពារប្រភពទ្រទ្រង់ជីវិតដោយត្រូវចូលរួមថែរក្សាការពារអភិរក្សនិអភិវឌ្ឍព្រៃឈើឲ្យ មានប្រសិទ្ធភាពនិងនិរន្តរភាពដើម្បីជាប្រយោជន៍ដល់មនុស្សជាតិយើងជំនាន់បច្ចុប្បន្ននិងជំនាន់ ក្រោយៗ ទៀត។

ដោយសារធនធានព្រៃឈើផ្តល់នូវសារប្រយោជន៍យ៉ាងធំធេងបែបនេះរដ្ឋបាលព្រៃឈើនៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តកម្មវិធីកំណែទម្រង់ព្រៃឈើដូចមានចែងក្នុងយុទ្ធ សាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលបានចាត់ទុកការងារសហគមន៍ព្រៃឈើជាការងារអាទិភាព ក្នុងការគ្រប់គ្រងព្រៃឈើ។

រដ្ឋបាលព្រៃឈើមានសេចក្តីសោមនស្សរីករាយ សូមបង្ហាញនូវទិន្នន័យសហគមន៍ព្រៃឈើនៅ កម្ពុជា តាមរយៈសៀវភៅ "**ស្ថិតិសហគមន៍ព្រៃឈើកម្ពុជាឆ្នាំ២០១៣**" សម្រាប់ជាមូលដ្ឋានក្នុងការ រៀបចំកម្មវិធី និងផែនការសកម្មភាពអភិវឌ្ឍសហគមន៍ព្រៃឈើក៏ដូចជាការអភិវឌ្ឍ ការអភិរក្ស ការ សិក្សាស្រាវជ្រាវការប្រើប្រាស់ផល អនុផលព្រៃឈើ និងសេវាកម្មផ្សេងៗទៀត។

រដ្ឋបាលព្រៃឈើមានកិត្តិយសសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍នានា សង្គមស៊ីវិលជាតិនិងអន្តរជាតិ និងសហគមន៍មូល ដ្ឋានដែលចូលរួមឧបត្ថម្ភ គាំទ្រដល់ដំណើរការអភិវឌ្ឍសហគមន៍ព្រៃឈើនៅកម្ពុជាប្រកបដោយជោគ ជ័យ និងសូមថ្លែងអំណរគុណយ៉ាងអនេកចំពោះ អង្គការដៃគូទាំងអស់ដែលបានចូលរួមឧបត្ថម្ភក្នុង ការបោះពុម្ពសៀវភៅស្ថិតិនេះ។

**ឆេង គឹមស៊ុន**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## ២.១.សហគមន៍ព្រៃឈើនៅខេត្តកែប

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ៥៤៨ប្រក.កសក. ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០ ប្រកាសលេខ៦១២ប្រក.កសក. ចុះថ្ងៃទី០៥ខែធ្នូឆ្នាំ២០១១ និងប្រកាសលេខ០៧២ ប្រក.កសក. ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកែប។

### តារាង៣ ៖ ស្ថិតិសហគមន៍ព្រៃឈើខេត្តកែប, មិថុនា ២០១៣

| ល.រ | ឈ្មោះ ស.ព | ផ្ទៃដីព្រៃ (ហ.ត) | ឃុំ | ស្រុក | ចំនួនភូមិ | គ្រួសារសមាជិក | ថ្ងៃ ខែ ឆ្នាំ ក.ស.ក | ថ្ងៃ ខែ ឆ្នាំ កិច្ចព្រម |
|---|---|---|---|---|---|---|---|---|
| ១ | ភ្នំពោន | ៦០,០០ | ពងទឹក | ដំណាក់ចង្អើរ | ១ | ៣៩៥ | ២០.០៨.១០ | ១៧.១២.១០ |
| ២ | ដំណាក់ចង្អើរ | ៥៨៣,០០ | ព្រៃធំ | កែប | ១ | ៣៨៥ | ០៥.១២.១១ | |
| ៣ | ចំការបី | ៣៦៦,០០ | ពងទឹក | ដំណាក់ចង្អើរ | ២ | ៣១៨ | ១៩.០២.១៣ | |
| សរុប | | ១.០០៩,០០ | ២ | ២ | ៤ | ១.០៩៨ | ៣ | ១ |

### រូបភាពទី៣ ៖ ផែនទីទីតាំងព្រៃសហគមន៍ខេត្តកែប, មិថុនា ២០១៣

